BMI0115

# សម្ភាសន៍ជាមួយតាចាំ ភេទប្រុស អាយុ៦៦ឆ្នាំ
# មុខងារសម័យខ្មែរក្រហមៈ ប្រជាជនមូលដ្ឋាន
# រស់នៅភូមិគំរូ ឃុំគំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
# ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០
# សម្ភាសន៍ដោយៈ ជា ផល្លា
# ០០:២៨:៥៤
# ១២ទំព័រ

ផល្លាៈ អ៊ំឈ្មោះអីដែរ?

ចាំៈ ឈ្មោះតា ចាំ ។

ផល្លាៈ តា ចាំ? ឈ្មោះពេញម៉េចដែរអ៊ំ?

ចាំៈ តា ចាំ!

ផល្លាៈ អ៊ំអាយុប៉ុន្មានដែរ?

ចាំៈ អាយុ៦៦ឆ្នាំ ។

ផល្លាៈ ៦៦! អ៊ំរស់នៅភូមិឃុំអីដែរ?

ចាំៈ នៅភូមិគំរូ ។

ផល្លាៈ ភូមិគំរូ? ឃុំ?

ចាំៈ ឃុំគំរូ

ផល្លាៈ ស្រុក?

ចាំៈ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

ផល្លាៈ ខេត្តបន្ទាយមានជ័យ?

ចាំៈ បាទ!

ផល្លាៈ អ៊ំខ្ញុំចង់ឲ្យអ៊ំជួយរៀបរាប់ពីប្រវត្តិអ៊ំបន្តិច កាលណ្ហឹងមិនជំនាន់លន់ នល់ ដល់ជំនាន់លន់ នល់ ហើយមិនខ្មែរក្រហមចូលម៉ោអ៊ំនេះ?

ចាំៈ កាលជំនាន់លន់ នល់ខ្ញុំមិនបានធ្វើការទេ មិនបានធ្វើទាហានមិនបានធ្វើអីទេ ។

ផល្លាៈ ចឹងធ្វើអីទៅអ៊ំ?

ចាំៈ ធ្វើតែស្រែចំការ ។

ផល្លា៖	ធ្វើស្រែចំការ អ៊ឹមានបងប្អូនប៉ុន្មាននាក់ចឹង?

ចាំ៖	មានបងប្អូនពីនាក់ ខ្ញុំពីដើមឡើយនៅវត្តចាស់ក៏បានប្រពន្ធនៅនេះ ។

ផល្លា៖	ភូមិកំណើតនៅណាអ៊ឹ?

ចាំ៖	ភូមិកំណើតនៅភូមិវត្តចាស់ ។

ផល្លា៖	ភូមិវត្តចាស់?

ចាំ៖	ដល់ហើយបានប្រពន្ធនៅភូមិគំរូ ។

ផល្លា៖	ដល់ហើយបានប្តូរមកនៅភូមិគំរូពេលដែលការប្រពន្ធហើយ?

ចាំ៖	បាទ!

ផល្លា៖	ចឹងអ៊ឹការប្រពន្ធនៅឆ្នាំប៉ុន្មានដែរ?

ចាំ៖	តាំងពីសាធារណៈរដ្ឋ ។

ផល្លា៖	អ៊ំតាំងពីសាធារណៈរដ្ឋ?

ចាំ៖	តាំងពីសម្តេច.... យូហើយឥលូវវា៦៦គិតមើល ។

ផល្លា៖	អាយុ៦៦ ការតាំងពីអាយុប៉ុន្មានអ៊ឹ?

ចាំ៖	ប្រហែលជាអាយុ២២ ។

ផល្លា៖	ប្រហែលជាអាយុ២២ ចាំ!តាំងពីជំនាន់សាធារណៈ ។

ចាំ៖	មុនលន់ នល់ធ្វើរដ្ឋប្រហារទៀត ។

ផល្លា៖	ណ្ហឹងអើយជំនាន់សម្តេចសីហនុ ហ៏គ្រួសារអ៊ឹពេលការហើយរកស៊ីអីដែរអ៊ឹ?

ចាំ៖	រកស៊ីធ្វើស្រែ ។

ផល្លា៖	ធ្វើស្រែចំការដដែល?

ចាំ៖	ហើយខ្ញុំមិនបានចេះអក្សរចេះអីនឹងគេ ។

ផល្លា៖	អ៊ំចឹងអ៊ឹអត់ដែលបានរៀនអក្សអីនឹងគេសោះ?

ចាំ៖	អត់ទេ! មានតែគោមេ អត់ដែលបានរៀនសូត្រទេ ទាហានក៏មិនដែលបានប៉ះដែរបានអី ខ្ញុំនៅតែផ្ទះនៅតែសម្រានចាស់ប៉ុននេះហើយ ។

ផល្លា៖	ចាំ!

ចាំ៖	មិនដែលមានប៉ះពាល់អី កន្ទេបកន្ទុបស្រីៗអីមិនដែលបានប៉ះនឹងគេទេ ហើយចឹងឯងវាមិនចេះ ហើយគេយកទៅធ្វើអី គេរើសយកទៅធ្វើការហើយខ្ញុំមិនចេះមានអ្នកណាគេរើស ធ្វើតែស្រែ ចំការចិញ្ចឹមកូនមិនចង់នឹងរស់ផង ។

ផល្លា៖ ចឹងកាលណ្ហឹងអ៊ីមានកូនប៉ុន្មាននាក់?

ចាំ៖ កូននៅសព្វថ្ងៃនេះមាន៦នាក់ ។

ផល្លា៖ ចឹងដល់ពេលនៅក្នុងភូមិណ្ហឹងអត់មានអីមុនរបបខ្មែរក្រហមចូលម៉ោដល់ទេ នៅក្នុងណ្ហឹងអត់អីទេអ៊ឺ អត់មានវ៉ៃគ្នាអីទេ?

ចាំ៖ វ៉ៃ!

ផល្លា៖ វ៉ៃនៅណាដែរ?

ចាំ៖ នៅក្នុងភូមិ ។

ផល្លា៖ ភូមិណាអ៊ឺ?

ចាំ៖ ភូមិគុំរូណ្ហឹង ហើយគេវ៉ៃគេចូលម៉ោ ។

ផល្លា៖ ពីណាចូលមកវ៉ៃជាមួយជាពីណា?

ចាំ៖ ចូលម៉ោកងទ័ពវៀតណាម ។

ផល្លា៖ វៀតណាម?

ចាំ៖ គេរំដោះ ឃើញវៀតណាមគេរំដោះបានខ្មែរក្រហម.... ខ្ញុំគេចាប់ចងយកទៅម្កាក់ ។

ផល្លា៖ អាណ្ហឹងពេលឆ្នាំ អ៊ឺអាណ្ហឹងពេលឆ្នាំ៧៥ ។

ចាំ៖ ឆ្នាំ៧៨ហើយ សន្តិភាពហើយណ្ហឹង ។

ផល្លា៖ អ៊ំអ៊ឺខ្ញុំចង់ឲ្យអ៊ីរៀបរាប់ឲ្យបានច្បាស់បន្តិចតាំងពី៧៤,៧៥ម៉ោចឹងណាំ ។

ចាំ៖ ៧៤,៧៥ម៉ោទៅនៅក"៥" ។

ផល្លា៖ អាណ្ហឹងពេល៧៥ប៉ុក៏ម៉េច ៧៥ពេលខ្មែរក្រហមចូលម៉ោអី?

ចាំ៖ ខ្មែរក្រហមគេកាន់កាប់ ។

ផល្លា៖ ពេលខ្មែរក្រហមកាន់កាប់ភ្លាមគេបញ្ជូនអ៊ីទៅណាដែរអ៊ឺ?

ចាំ៖ ទៅឯបន្ទាយឆ្មានោះ ។

ផល្លា៖ ភូមិបន្ទាយឆ្មា?

ចាំ៖ បាទ! ភូមិបន្ទាយឆ្មា ។

ផល្លា៖ ភូមិបន្ទាយឆ្មា ឃុំ?

ចាំ៖ ឃុំបន្ទាយឆ្មាណ្ហឹងឯង ។

ផល្លា៖ ស្រុក?

ចាំ៖ ស្រុកថ្មពួក ។

ផល្លា៖	គេជម្លៀសអ៊ីទៅណ្ហីងហ្នឹងអ៊ឺ ក៏យើងដូរទៅខ្លួនយើង?

ចាំ៖	ប្រពន្ធកូននៅណ្ហីងឯងគ្រាន់តែគេឲ្យខ្ញុំទៅធ្វើការ ទៅធ្វើស្រែចំការពង្រាបដីពង្រាបអី ធ្វើស្រែមួយហិចតាពីហិចតា ។

ផល្លា៖	អ៊ំចឹងកាលណ្ហឹងអ៊ំទៅណ្ហឹងនៅក្នុងកងអីដែរ ពេលទៅដល់បន្ទាយឆ្មាណ្ហឹង?

ចាំ៖	នៅក្នុងកងភ្នូរ ។

ផល្លា៖	កងភ្នូរ?

ចាំ៖	បាទ!

ផល្លា៖	មានគ្នាប៉ុន្មាននាក់ដែរកងណ្ហឹង?

ចាំ៖	កងភ្នូរមាន៣០នាក់ កាន់ក្តាប់មួយទៅប្រធានក្រុម ។

ផល្លា៖	ប្រធានក្រុមឈ្មោះអីគេ?

ចាំ៖	អាស៎?

ផល្លា៖	អ៊ឺជា?

ចាំ៖	ភ្លេចអស់ហើយ ។

ផល្លា៖	ប្រធានក្រុមឈ្មោះអីដែរ?

ចាំ៖	ប្រធានក្រុមវាងាប់អស់ហើយ ។

ផល្លា៖	ចាំ! ខ្ញុំគ្រាន់ចង់ដឹងឈ្មោះដើម្បី... ។

ចាំ៖	កាលណ្ហឹងការដ្ឋានមកពីអីណាណីនោះ មកពីស្វាយនេះអាស្វាយចេកយើងនេះ តាបែនពូវេន មករួមគ្នាទៅនៅការដ្ឋានណ្ហឹង អាណាគេចេះដឹងចឹងគេធ្វើប្រធានក្រុមកាន់ក្តាប់ ។

ផល្លា៖	ចុះអ្នកនៅកាន់ក្តាប់នៅប្រធានភូមិប្រធានក្រុមណ្ហឹងឈ្មោះអីគេដែរអ៊ំ ដឹងទេអ៊ំ?

ចាំ៖	ប្រធានភូមិ ដែលធ្វើប្រធានភូមិណ្ហឹងគេប្រជាជនអាពត ។

ផល្លា៖	ចាំ!

ចាំ៖	គណៈស្រុកក៏ប្រជាជនអាពតឈ្មោះតា សាំ ។

ផល្លា៖	តាសាំ? គាត់គណៈស្រុក? គាត់ធ្វើអីគេដែរ?

ចាំ៖	គាត់ប្រធានភូមិ ។

ផល្លា៖	ភូមិអីគេដែរ?

ចាំ៖	ភូមិគំរូណ្ហឹង ។

ផល្លា៖	ភូមិគំរូណ្ហឹងឈ្មោះតាសាំ?

ចាំៈ បាទ! ដឹងទៅណាទេ ប្រជាជនជម្លៀសម៉ោ ។

ផល្លាៈ ចុះអ៊ីវិញ ពូថាគេឲ្យអ៊ីធ្វើអីដែរអ៊ីអ៊ឹ ធ្លាប់ធ្វើអីដែរអត់ទេ កាន់កងកាន់អីដែរអត់ទេអ៊ឹ?

ចាំៈ ទេខ្ញុំមិនបេះទៅកាន់ម៉េចកើត ។

ផល្លាៈ ចឹង? អត់ទេកាន់កងគ្រាន់តែធ្វើស្រែធ្វើអីចឹងគ្រាន់តែយើងអីចឹងណ៎ា ។

ចាំៈ ដូចថាយើងចាស់ជាងគេ នាំបងប្អូនពង្រាបដីពង្រាបអីចឹងណ៎ា មើលការខុសត្រូវខ្លះចឹងទៅ ។

ផល្លាៈ អ៎គេឲ្យអ៊ីមើលណោះ? គេឲ្យមើលប៉ុន្មាននាក់ដែរ?

ចាំៈ ពីរបីនាក់ទៅ ។

ផល្លាៈ ចឹងគេអ៊ីមើលគ្នាប៉ុន្មាននាក់ដែរ?

ចាំៈ បីបួនប្រាំនាក់ ។

ផល្លាៈ ចឹងអ៊ឹអត់មានទៅសរមភូមិទៅអីទេណោះ?

ចាំៈ ទៅពីផ្ទះនេះទៅនៅបន្ទាយឆ្នាណ្ហឹង ។

ផល្លាៈ ទៅបន្ទាយឆ្នាណ្ហឹងធ្វើអីខ្លះ?

ចាំៈ ដែលខ្ញុំថាពង្រាបដី ធ្វើស្រែណ្ហឹង ។

ផល្លាៈ តែប៉ុណ្ហឹងទេ?

ចាំៈ ពង្រាបដីរួចស្ងួត អាស្រួចអីអ៊ាយើងណ្ហឹង ។

ផល្លាៈ ចា៎!

ចាំៈ ពង្រាបដីរួចស្ងួត ស្ងួតរួចចឹងទៅដល់ពេលហើយយកភោគផលម៉ោដាក់សហករណ៍ ។

ផល្លាៈ ធ្វើរហូតហ្នឹងអ៊ីប្ដូរក៏ម៉េច? ធ្វើរហូតពឆ្នាំ៨ខែធ្វើតែស្រែនៅណ្ហឹងប្ដូរក៏គេដូរទៅណាទៀត?

ចាំៈ គ្មានដូរទៅណាទេ!

ផល្លាៈ អត់ដូរទៅណាទេ?

ចាំៈ នៅធ្វើតែស្រែណ្ហឹង គេដូរតើគេដូរឲ្យខ្ញុំធ្វើខាងដឹកជញ្ជូនឲ្យកាន់រទេះគោក្របី ដឹកជញ្ជូនយក
ភោគផលម៉ោពីនោះដាក់នេះ ។

ផល្លាៈ យកមកភូមិគុំរូនេះ?

ចាំៈ បាទ!

ផល្លាៈ អ៊ឹមានដែលស្គាល់យាយថែមអីទេ? អ៊ឹថែមអីអ៊ឹ គាត់ប្រធាននៅខាងត្រពាំងថ្មអ៊ឹមានដែល
ឃើញទេ?

ចាំៈ មិនដែលឃើញទេ ឃើញតែគេប្រធានសហករណ៍គេ ។

ផល្លា៖ ណ្ហឹងអើយប្រធានសហករណ៍ ប្រធានសហករណ៍ឈ្មោះអីគេអ៊ឹ?

ចាំ៖ ប្រធានសហករណ៍ឈ្មោះតាបេន។

ផល្លា៖ តាបេនប្រធានសហករណ៍?

ចាំ៖ បាទ!

ផល្លា៖ ចុះអនុគាត់ឈ្មោះអីគេដែរអ៊ឹ?

ចាំ៖ អនុណ្ហឹងគេវៃចោលអស់ហើយ។

ផល្លា៖ ម៉េចបានគេវៃចឹងអ៊ឹ?

ចាំ៖ ចុះកាលណ្ហឹងគេជម្លៀស! ដកដូចថាទៅរៀនយកគ្នាទៅវៃចោល។

ផល្លា៖ ចុះពុថាមានពួកនារតីចូលម៉ោអ៊ឹ?

ចាំ៖ ណ្ហឹងអើយពួកនារតីណ្ហឹង នារតីចូលម៉ោដកអានារតីចាស់យកទៅវៃចោល យកទៅវៃបន្ត បន្ទាប់។

ផល្លា៖ ចឹងអ៊ឹពេលពួកនារតីចូលម៉ោណ្ហឹងមានអីកើតឡើងនៅក្នុងភូមិណ្ហឹងទេ សកម្មភាពអីប្លែក?

ចាំ៖ មានប្លែកអី មានតែប្រជុំហើយធ្វើការវាល់ៗល្ងាច អារឿងធ្វើបាបធ្វើអីណ្ហឹងខ្ញុំអត់ដឹងទេ ឃើញតែគេឲ្យទៅរៀនសូត្រកូនចៅខ្ញុំបងប្អូនខ្ញុំ ទៅបាត់ជ្រាបៗរហូតទាល់សព្វថ្ងៃណ្ហឹង គេថាទៅឲ្យដាំកប្បាសនៅណាស្វាយស៊ីសុផុនណោះ ហើយបាត់អស់មិនដឹងគេយកទៅវៃចោលឬម៉េច។

ផល្លា៖ ចឹងអាជំនាន់៣ឆ្នាំជាងណ្ហឹងអ៊ឹអត់មានបានជួបគ្រួសារអ៊ឹសោះ?

ចាំ៖ ទេដេកផ្សេងគ្នា។

ផល្លា៖ ដេកផ្សេ ងគ្នា?

ចាំ៖ គ្រួសារគេឲ្យទៅលើកថ្នល់ លើកទំនប់ប្រឡាយ ខ្ញុំគិតតែនៅធ្វើស្រែធ្វើចំការណោះតែឯង គេចាត់តាំងដោយឡែកៗមិនអាចនៅជុំគ្នាបានទេ អាកូនចៅដូចខាងនាងឯងចឹងទៅនៅគេហៅកងចល័តលើកទំនប់ប្រឡាយ ធ្វើដូចថាប្រឡាយត្រពាំងថ្ម។

ផល្លា៖ ចុះអ៊ឹមានបានទៅលើកណ្ហឹងដែរអត់ទេ?

ចាំ៖ ទេខ្ញុំមិនបានទៅទេ!

ផល្លា៖ អ៊ឹនៅតែបន្ទាយឆ្មាណ្ហឹង?

ចាំៈ បាទ! គេចាត់ការទៅនោះ ហើយអាគេអ្នកចល័តទៅ ប្រជាជនយុវជន យុវនារីគេទៅលើកផ្ទាំងថ្ម ហើយខ្ញុំនៅតែបន្ទាយឆ្មា គ្រួសារខ្ញុំគេដកស្ទូងតាមភូមិ គេធ្វើស្រែតាមភូមិ ។ អារឿង អត់ឃ្លានៗ ហើយពិបាកនិយាយណាស់ បាយបបរប៉ុននេះក៏មាន ។

ផល្លាៈ ចុះអត់មានតវ៉ាតអីទេអ៊ឺ បាយដាក់ឲ្យអត់គ្រប់?

ចាំៈ តវ៉ាម៉េចកើតជំនាន់ណ្ហឹង ហើយយើងតវ៉ានឹងគេម៉េចបានមិនថានាងឯងមិនថាខ្ញុំ ។

ផល្លាៈ ចា៎!

ចាំៈ មិនហ៊ានតវ៉ា ឲ្យនៅកសាងនៅដាំអំពៅដាំអី មានគេលួចអំពៅមួយដើមមកស៊ីគេស៊ីតាមចិត្ត ខ្ញុំហ៊ានស៊ីតែខ្ទាំងៗ សល់អាខ្ទាំងណ្ហឹងតែគេមិនឲ្យស៊ីផង ។

ផល្លាៈ ចឹងអ៊ឹពេលដែលគេឲ្យធ្វើស្រែណ្ហឹងស្ថិតនៅក្នុងកងអីដែរ កងណ្ហឹងឈ្មោះកងអីគេ?

ចាំៈ កងចល័ត ។

ផល្លាៈ កងចល័តអ៊ឹណោស៎?

ចាំៈ បាទ!

ផល្លាៈ ចឹងអ៊ឹនៅក្នុងកងចល័ត កងចល័តណ្ហឹងមានគ្នាប៉ុន្មាននាក់?

ចាំៈ ៦០ នាក់ ។

ផល្លាៈ ៦០ នាក់?

ចាំៈ បាទ! មួយចល័តៗទៅនៅធ្វើស្រែ ។

ផល្លាៈ ធ្វើស្រែហើយឮថាមានជីកទៅណាធ្វើលើកប្រឡាយលើកទំនប់អីណាឆ្ងាយអីអត់មានទេអ៊ឹ?

ចាំៈ អត់ទេមានតែបិទភ្លឺបំប៉ន់ភ្លឺ បំប៉ន់ភ្លឺណ្ហឹងធ្វើប្រឡាយណ្ហឹងអើយ ។

ផល្លាៈ នៅណានៅបន្ទាយឆ្មាណ្ហឹង?

ចាំៈ នៅបន្ទាយឆ្មា ។

ផល្លាៈ ភូមិណា?

ចាំៈ ភូមិសង្កើច ខាងកើតជើងជ្រោះ ។

ផល្លាៈ លើកប្រឡាយនៅខាងកើតជើងជ្រោះ?

ចាំៈ បាទ!

ផល្លាៈ ចឹងអ៊ឹនៅក្នុងកងចល័តណ្ហឹងធ្វើស្រែហើយអត់មានធ្វើអីទៀតទេអ៊ឹ?

ចាំៈ ធ្វើអីទៀតមានតែប៉ុណ្ហឹង មានតែអូសគោក្របីតែប៉ុណ្ហឹងឯង ។

ផល្លាៈ ចឹងអ៊ឹអត់មានចូលធ្វើកងធ្វើទេអ៊ឹ?

ចាំៈ ធ្វើកងអីបើខ្ញុំមិនចេះអក្សផង អ្នកណាគេយកធ្វើប្រធានកង កងគេត្រូវតែចុះបញ្ជីថានារីមានប៉ុន្មាន យុវជនមានប៉ុន្មាន វ័យចំណាស់មានប៉ុន្មាន? មិនមែនចេះតែធ្វើទេច្រឡូកច្រឡំរបស់គេ ។

ផល្លាៈ ចាំ!

ចាំៈ យើងអ្នកមិនចេះអក្សគេគិតតែពីប្រើធ្វើស្រែទៅ ឲ្យតែគេប្រើ បើគេមិនប្រើទេយើងធ្វើការតែលើកភ្លឺណ្ហឹងទៅ ។

ផល្លាៈ ចឹងអីអត់មានបងប្អូនអីស្លាប់ទេអី បងប្អូនឪពុកម្ដាយអី?

ចាំៈ ស្លាប់ជិនាន់ប៉ុល ពត ឪខ្ញុំគាត់ស្លាប់បងប្អូនគេឲ្យទៅដាំកប្បាសនៅស្វាយស៊ីសុផុនណោះពូខ្ញុំថា ទេទៅបាត់ជ្រាប ។

ផល្លាៈ ចាំ!

ចាំៈ ទាំងប្ដីទាំងប្រពន្ធកូនទាំងអស់ ។

ផល្លាៈ ប៉ុន្មាននាក់អី?

ចាំៈ បីបួននាក់ ។

ផល្លាៈ បីបួននាក់បងប្អូនបង្កើតឬក៏?

ចាំៈ បងប្អូនខ្ញុំបង្កើត ។

ផល្លាៈ បងប្អូនបង្កើតម្នាក់?

ចាំៈ គេឲ្យទៅដាំកប្បាស ។

ផល្លាៈ ចាំ!

ចាំៈ យកទៅទាំងគោទាំងរទេះហើយថាទៅបង្កើតផល គោក្របីណ្ហឹងដឹងយកទៅចោលណា ។

ផល្លាៈ អាណ្ហឹងនៅឆ្នាំប៉ុន្មានដែរអី?

ចាំៈ ដឹងឆ្នាំប៉ុន្មានទេខ្ញុំមិនបានគិតគូរអារឿងណ្ហឹង ។

ផល្លាៈ ចឹងម៉េចអីដឹងថាគេឲ្យគាត់ទៅរៀនសូត្រ?

ចាំៈ ចុះប្អូនវាប្រាប់នោះ! គេប្រធានភូមិនោះគេថាគេចាត់តាំងឲ្យទៅដាំកប្បាសនៅស្វាយអ្នកស្រុកគេនៅនោះឯង ។

ផល្លាៈ ចឹងគាត់ទៅណ្ហឹងទៅមួយគ្រួសារគាត់ឬម៉េចអី?

ចាំៈ គេទៅដូចថាមួយភូមិគុំរូចឹងប៉ុន្មានគ្រួសារ? ៥គ្រួសារ ភូមិមាត់ចាស់៥គ្រួសារ ភូមិថ្មីពួក៥គ្រួសារនាំគ្នាទៅទាំងប្រពន្ធទាំងកូនឲ្យទៅ គេថាឲ្យទៅដាំកប្បាសដាំអីយកផល ដាំអានេះដាំអានោះនៅស្រែចំការណ្ហឹងលេងគេយកទៅវ៉ៃចោលមានអាណាដឹង មានម៉ោវិញណា ។

ផល្លាៈ ចឹងប្អូនអ៊ឹតែម្នាក់ឬក៏ប៉ុន្មាននាក់បើគិតមើលទៅ?

ចាំៈ ប្អូនខ្ញុំវាតែម្នាក់ទេ ប៉ុន្តែកូនវាពីរបីនាក់ ។

ផល្លាៈ ចា៎!

ចាំៈ ហើយប្តីវាផងអីផង!

ផល្លាៈ ចុះឪពុកម្តាយអ៊ឹ?

ចាំៈ ឪពុកម្តាយខ្ញុំងាប់ប៉ុល ពតមួយនៅមួយ ម៉ែខ្ញុំងាប់កាលប៉ុល ពត គាត់ងាប់អាយុ១០០ ។

ផល្លាៈ ចឹងឪពុកអ៊ឹស្លាប់ដោយសារអីដែរអ៊ឹ ឪពុកអ៊ឹស្លាប់ដោយសារអីនៅជំនាន់ណ្ហឹង?

ចាំៈ ស្លាប់ដោយសារប៉ុល ពត ។

ផល្លាៈ គាត់..?

ចាំៈ គាត់ស្លាប់សោយអត់បាយ គាត់ដាច់ពោះ ។

ផល្លាៈ ចឹង? កាលណ្ហឹងគាត់នៅភូមិឃុំណ្ហឹងដែរអត់ទេ?

ចាំៈ គាត់នៅភូមិមាត់ចាស់ ។

ផល្លាៈ ភូមិអីគេ?

ចាំៈ ភូមិមាត់ចាស់ គាត់ពុលដំឡូងគ យកសំបកដំឡូងគគេម៉ោដល់ស៊ីទៅវាពុល ដល់ឪពុកដាច់ខ្យល់ ទៅម៉ែណ្ហឹងគាត់លើកឪពុកអត់រួច ដល់លើកគាត់រួចចាប់លីកតែម្តងដើងអូសដី ដល់ហើយទៅ ជីករណ្តៅកប់តែម្នាក់ឯងទៅ ។

ផល្លាៈ ចឹងដល់ក្រោយម៉ោពេលវៀតណាមចូលម៉ោអ៊ឹទៅណាដែរចឹង?

ចាំៈ គេជម្លៀសទៅម្កាក់ ។

ផល្លាៈ នៅណាម្កាក់ណ្ហឹងអ៊ឹ ភូមិឃុំអី?

ចាំៈ ភូមិម្កាក់ណ្ហឹង ។

ផល្លាៈ ភូមិម្កាក់ ឃុំ?

ចាំៈ នៅស្មាយ ។

ផល្លាៈ ចា៎!

ចាំៈ គេឲ្យទៅនៅណ្ហឹង គេជម្លៀសទៅណ្ហឹង ។

ផល្លា៖ ចាំ!

ចាំ៖ កាលណ្ហើងប៉ុល ពតគេយកទៅគេកៀរទៅ វៀតណាមគេកៀរទៅ ។

ផល្លា៖ វៀតណាមណ្ហើងកៀរខាងអ៊ំណ្ហើងយកទៅ?

ចាំ៖ ទៅនៅម្កាក់ ។

ផល្លា៖ ទៅនៅម្កាក់ហើយចុះប្រពន្ធអ៊ំអី?

ចាំ៖ ទៅទាំងអស់គ្នា ។

ផល្លា៖ ទៅទាំងអស់គ្នា?

ចាំ៖ គេកៀរទៅទាំងអស់ ។

ផល្លា៖ ហើយកៀរទៅណ្ហើងម៉េចទៀតទៅអ៊ំ នៅណ្ហើងរស់នៅម៉េចទៅអ៊ំ?

ចាំ៖ ខ្ញុំគ្រួសារគេកៀរទៅ ខ្ញុំគេចាប់ គាត់មួយនៅស្រុកក៏គេចាប់គេចាប់ដូចគ្នាព្រោះគេឯងប៉ុល ពត ។

ផល្លា៖ ចាំ!

ចាំ៖ ចាប់កៀរយកទៅដាក់គុកនៅស្វាយសុីសុផុនណ្ហើង ។

ផល្លា៖ ចាំ! ពីណាអ្នកចាប់?

ចាំ៖ ពួកវៀតណាមណ្ហើងគេថាឯងប៉ុល ពត ។

ផល្លា៖ ម៉េចចឹងអ៊ំ?

ចាំ៖ ចុះយើងនៅខាងប៉ុល ពត គាត់មិនទាន់រំដោះណាហ៊ុនសែនគាត់មិនទាន់រំដោះបានណា ដល់ពេលវ៉ៃរំដោះម៉ោគេចាប់បាន ។

ផល្លា៖ ធម្មតាគេចាប់តែមេហើយអ៊ំធ្វើនៅកងចល័តមិនដែលគេចាប់?

ចាំ៖ ចាប់ទាំងភូមិតែម្តងណាំ ចាប់យកទៅសួថាអ្នកណាអ្នកធ្វើអ្នកណាមិនធ្វើ ចាប់បានមួយអាទិត្យពីរអាទិត្យគេលែងមកវិញ

ផល្លា៖ ចឹង ហើយគេមានធ្វើបាបអីអត់ចឹង?

ចាំ៖ គេមានធ្វើបាបអីគេគ្រាន់តែសួចម្លើយ ។

ផល្លា៖ ចាំ!

ចាំ៖ វាសួថាធ្វើអីកាលណ្ហើង? ហើឆ្លើយថាមិនបានធ្វើអីទេប្រជាជនមិនបានធ្វើប៉ុល ពតទេធ្វើតែស្រែធ្វើតែចំការ ។

ប៊ុនថន៖ ចុះអ៊ំគាត់ខាងនេះដែរ គាត់ធ្វើអីដែរ?

ចាំៈ គាត់ខាងស្រុក ។

ប៊ុនថនៈ គាត់ខាងស្រុកអីវិញ?

ចាំៈ ស្រុកថ្មពួក ។

ប៊ុនថនៈ ស្រុកថ្មពួក?

ចាំៈ គាត់ខាងសាខាស្រុកនៅនោះឯង ។

ប៊ុនថនៈ បាទ! តែគាត់ខាងកងទ័ព ។

ចាំៈ គាត់ខាងទាហ៊ានទេ!

ប៊ុនថនៈ បាទ!ខាងកងទ័ពរំដោះ អាស៊ខាងតស៊ូ ។

ផល្លាៈ ហើយមានទៅថៃទៅអីអត់ទេ?

ចាំៈ ទេរត់ធ្វើអី!

ផល្លាៈ ចឹងពេលគេលែងអ៊ំហើយអ៊ំមកនៅស្រុកភូមិណាវិញចឹង?

ចាំៈ ស្រុកភូមិឯងនេះ ។

ផល្លាៈ ចឹងត្រលប់មកភូមិគំរូនេះវិញ?

ចាំៈ ណ្ហឹងអើយ!

ផល្លាៈ ហើយម៉េចទៀតទៅ?

ចាំៈ ឡើងអស់ស័ក្ដសី គេជម្លៀសទៅម្នាក់គេរើសយកអស់ អាអ្នកដែលគេមិនបានទៅណ្ហឹង ។

ផល្លាៈ វៀតណាមជម្លៀសទៅម្នាក់ពេលណាបានអ៊ំចូលម៉ោភូមិនេះវិញ វៀតណាមឲ្យចូលម៉ោប្តូមួយក៏អ៊ំចូលម៉ោខ្លួនឯង?

ចាំៈ វៀតណាមគេឲ្យម៉ោវិញ ។

ផល្លាៈ វៀតណាមឲ្យម៉ោវិញ?

ចាំៈ ណ្ហឹងអើយ!

ផល្លាៈ ប៉ុន្មានខែបានឲ្យម៉ោវិញ?

ចាំៈ មួយខែ! ទៅនៅណ្ហឹងរុយក៏រុយអាចម៍ក៏អាចម៍ស៊ីបាយតែកន្ទែងណ្ហឹង ។

ផល្លាៈ ចុះអ៊ំពេលចូលនៅភូមិនេះវិញខ្មែរក្រហមមានដែលចូលមកធ្វើបាបអីដែរអត់ទេអ៊ំ?

ចាំៈ អត់ទេមិនដឹងទៅណាអស់ហើយ ឃើញតែពួកប៉ារ៉ាម៉ោ ។

ផល្លាៈ ពួកប៉ារ៉ាណ្ហឹងម៉ោធ្វើអ៊ី?

ចាំៈ វាមកវៃគ្នា វៃគ្នាជាមួយពួកហ៊ុនសែនណ្ហឹង ។

ផល្លាៈ ចា៎! ខ្មែរក្រហមមានឃោសនាអីនៅក្នុងភូមិទៀតទេអ៊ឹ?

ចាំៈ អត់!

ផល្លាៈ អត់នៅទេអ៊ឹ?

ចាំៈ នៅតែពេលបង្កើតក្រុម ។

ផល្លាៈ ពីណាបង្កើតក្រុមអ៊ឹ? បង្កើតនៅណាអ៊ឹ? ក្រោយម៉ោម៉េចទៀតអ៊ឹក្រោយ៧៩វៀតណាមចូលម៉ោហើយនៅបង្កើតទៀត?

ចាំៈ គេលែងហើយ គេរត់ចោលបាយចោលអីអស់ ប្រធានក្រុមស្រីខ្ញុំថាគេយកទៅវៃចោលអស់ហើយ អាកូនអាម្ដាយគ្នាទៅស្ទូងអស់អាកូននៅដាំបាយដាំទឹកឲ្យកូនស៊ីពេញៗមាត់ ចុះអាគ្នាកូនគ្នាដែលខ្ញុំធ្វើសកម្មធ្វើស្រែធ្វើចំការមិនឲ្យគ្នាស៊ីឆ្អែត ។

ផល្លាៈ ចឹងកូនអ៊ំអីមានស្លាប់នៅជំនាន់ណ្ហឹងទេអ៊ឹ កូនអីអត់អីណាអ៊ឹ?

ចាំៈ ងាប់ទាំងអស់កូន១២នាក់ងាប់ទាំងអស់ ។

ផល្លាៈ កូន១២នាក់ស្លាប់នៅជំនាន់ណ្ហឹងទាំងអស់?

ចាំៈ នៅ៦នាក់ ។

ផល្លាៈ ម៉េចចឹងអ៊ឹ ម៉េចបានងាប់?

ចាំៈ វាអត់បាយ ពួកក្មេងៗវាអត់បាយចុះមាននៅជុំគ្នាណាម៉ែវាគេឲ្យទៅចល័តស្ទូងដក ហើយកូនខ្ញុំមានណាមេដោះគេនៅថែរក្សាចាំមើលកុមារ ថែរក្សាឬមិនថែរក្សាស្រេចតែគេមានកូនគេណា ។

ផល្លាៈ ចឹងម៉ាជំនាន់៣ឆ្នាំណ្ហឹងស្លាប់អស់៦នាក់កូន?

ចាំៈ រស់៦នាក់ ។

ផល្លាៈ រស់៦ហើយស្លាប់ប៉ុន្មាននាក់?

ចាំៈ ១២នាក់ ។

ផល្លាៈ ១២នាក់ហើយស្លាប់អស់៦នាក់ចឹង?

ចាំៈ ៦នាក់ដូចតែគ្នាណ្ហឹង ។

ផល្លាៈ ចា៎!ស្លាប់៦នាក់នៅ៦នាក់ ច្រើនដែរចឹង?

ចាំៈ ច្រើន! កាលណ្ហឹងមានពេទ្យមានអីម៉ោពីណា គេសព្វថ្ងៃនេះតែនេះគេលេបថ្នាំលេបអី ។

ផល្លាៈ ចឹងអគុណច្រើនហើយអ៊ឹ ។

ចាំៈ បាទ!

«ចប់»